កម្មវិធីពិនិត្យសុខភាពទារក

ការពិនិត្យសុខភាពទារកគឺខុសពីការពិនិត្យសុខភាពមនុស្សពេញវ័យ និងតួនាទីរបស់អ្នកថែទាំគឺមានសារៈសំខាន់ជាពិសេស!

សេវាធានារ៉ាប់រងសុខភាពជាតិផ្តល់ការពិនិត្យសុខភាពតាមវ័យ (រួមទាំងការវាស់វែងរាងកាយ ការអប់រំសុខភាព ការវាយតម្លៃការអភិវឌ្ឍ និងការប្រឹក្សា) សម្រាប់ទារក និងកុមារតូចៗចាប់ពីអាយុ 14 ថ្ងៃដល់អាយុ 71 ខែ។ ការពិនិត្យសុខភាពទាំងនេះតាមដានយ៉ាងជិតដល់នូវដំណាក់កាលនៃការលូតលាស់ និងដំណាក់កាលនៃការអភិវឌ្ឍ ដើម្បីជួយការពារសុខភាពរបស់កុមារ។

ទិដ្ឋភាពទូទៅ

- **សិទ្ធិទទួលបាន**៖ ទារក និងកុមារតូចៗដែលមានអាយុក្រោម 6 ឆ្នាំ (អ្នកជាវធានារ៉ាប់រងសុខភាព និងអ្នកទទួលផលពីជំនួយផ្នែកវេជ្ជសាស្ត្រ)
- **គោលដៅ**៖ តាមដានដំណាក់កាលនៃការលូតលាស់ និងដំណាក់កាលនៃការអភិវឌ្ឍរបស់ទារក និងកុមារតូចៗ
- **ប្រភេទ**៖ ការពិនិត្យសុខភាពទារកទូទៅ (រួមទាំងការធ្វើតេស្តពិនិត្យការអភិវឌ្ឍ) និងការពិនិត្យសុខភាពធ្មេញ
- **ការចំណាយចេញពីហោរ៉ូ**៖ មិនគិតថ្លៃទេ ប្រសិនបើការពិនិត្យសុខភាពគឺស្ថិតនៅក្នុងរយៈពេលកំណត់

* ការជូនដំណឹងអំពីលទ្ធផលពិនិត្យសុខភាពទារក និងកុមារតូចៗអាចត្រូវបានប្រើសម្រាប់ដាក់ជូនមណ្ឌលថែទាំពេលវេជ្ជ និងសាលាមត្តេយ្យ។

ចំនួនដងនៃការពិនិត្យសុខភាព

ចំនួនដង	ទី 1	ទី 2	ទី 3	ទី 4	ទី 5	ទី 6	ទី 7	ទី 8
ការពិនិត្យសុខភាព	ពី 14 ទៅ 35 ថ្ងៃ បន្ទាប់ពីកើត	4 ទៅ 6 ខែ	9 ទៅ 12 ខែ	18 ទៅ 24 ខែ	30 ទៅ 36 ខែ	42 ទៅ 48 ខែ	54 ទៅ 60 ខែ	66 ទៅ 71 ខែ
ការពិនិត្យសុខភាពធ្មេញ	-	-	-	18 ទៅ 29 ខែ	30 ទៅ 41 ខែ	42 ទៅ 53 ខែ	54 ទៅ 65 ខែ	-

លក្ខខណ្ឌគោលដៅ

	ផ្នែកពិនិត្យសុខភាព*	វិធីពិនិត្យសុខភាព
វិបត្តិនៃការលូតលាស់	ការអភិវឌ្ឍយឺតយ៉ាវ លើសទម្ងន់ ដំដឹងតាក់ មីក្រូសេហ្វាលី (ក្បាលតូចខុសធម្មតា) និងម៉ាក្រូសេហ្វាលី (ក្បាលធំខុសធម្មតា)	ការវាស់វែងរាងកាយ៖ កម្ពស់ ទម្ងន់ និងរង្វង់ក្បាល
ភាពខុសប្រក្រតីនៃការអភិវឌ្ឍ	ពិការភាពផ្នែកបញ្ញា ដំដឹអ្ទិសីម ដំដឹពិការខួរក្បាល រំលត្តិភាសា និងរំលត្តិអាកប្បកិរិយា	ការធ្វើតេស្តការអភិវឌ្ឍ
គ្រោះថ្នាក់	គ្រោះថ្នាក់ចរាចរណ៍ ស្លាប់ទាន់ពាក់ពេលដេកលក់ ឮ គ្រោះថ្នាក់ភ្លើងដុះ លង់ទឹក និងពុល	ការអប់រំសុវត្ថិភាព និងការអប់រំដំណេក
អាហារូបត្ថម្ភ	កង្វះអាហារូបត្ថម្ភ និងអាហារូបត្ថម្ភលើស	ការអប់រំអំពីអាហារូបត្ថម្ភ
ភាពខុសប្រក្រតីនៃការស្តាប់	ការបាត់បង់ការស្តាប់	កម្រងសំណួរអំពីការធ្វើតេស្តពិនិត្យការស្តាប់
ការជះខ្សោយតាត់ហើញ	ដំដឹភ្នែកឡើងបាយពីកំណើត ដំដឹងដឹតភ្នែក (ភ្នែកខ្ជិល) ភ្នែកស្រលៀង (ភ្នែកកែក) ដំដឹម្ជុប(មើលឃើញតែជិត) និងដំដឹអាស្ទីម៉ាត	កម្រងសំណួរអំពីមុខងារតាត់ហើញ និងការពិនិត្យតាត់ហើញ និងភ្នែក
វិបត្តិនៃធ្មេញ	ដំដឹពុកធ្មេញ ដំដឹអញ្ចាញធ្មេញ(ធ្មេញកែជ និងការពារខុសប្រក្រតីនៃធ្មេញ	ការពិនិត្យសុខភាពធ្មេញ និងការអប់រំសុខភាពមាត់ធ្មេញ

*ផ្នែកពិនិត្យសុខភាព៖ សំដៅលើដំដឹទាំងឡាយដែលអាចបង្ការបានតាមរយៈការពិនិត្យសុខភាព

នីតិវិធីពិនិត្យសុខភាព

1 ស្វែងរកស្ថាប័នពិនិត្យសុខភាព

សូមប្រាកដថាត្រូវធ្វើការណាត់ជួបជាមុន ហើយបញ្ជាប់ការពិនិត្យសុខភាពក្នុងរយៈពេលដែលមាន ពីព្រោះការណាត់ជួបអាចប់ពេញមុនបានអាស្រ័យលើស្ថាប័នពិនិត្យសុខភាព។

- គេហទំព័រ (www.nhis.or.kr) → Health MOA → ស្វែងរកស្ថាប័នពិនិត្យសុខភាព/មន្ទីរពេទ្យ
- កម្មវិធីទូរសព្ទ (The Health Insurance) → Health MOA → ស្វែងរកស្ថាប័នពិនិត្យសុខភាព/មន្ទីរពេទ្យ (គ្លីនិក)

2 ការដាក់ពាក្យ

សូមយកអត្តសញ្ញាណប័ណ្ណរបស់អ្នកថែទាំ ឬប័ណ្ណធានារ៉ាប់រងសុខភាពមកជាមួយ

3 ប់ពេញកម្រងសំណួរ/ទម្រង់ធ្វើតេស្តពិនិត្យការអភិវឌ្ឍ

ប់ពេញជាមុននូវកម្រងសំណួរ/ទម្រង់ធ្វើតេស្តពិនិត្យការអភិវឌ្ឍតាមរយៈ គេហទំព័រ/កម្មវិធីទូរសព្ទ ឬនៅស្ថាប័នពិនិត្យសុខភាពនៅថ្ងៃពិនិត្យសុខភាព។

- **ប់ពេញជាមុននូវកម្រងសំណួរ/ទម្រង់ធ្វើតេស្តពិនិត្យការអភិវឌ្ឍ**
  - គេហទំព័រ NHIS (www.nhis.or.kr) → Health MOA → ការគ្រប់គ្រងសុខភាពគ្រួសារ → ឡកចូលដោយប្រើវិញ្ញាបនបត្រ → ប់ពេញកម្រងសំណួរ/ទម្រង់ធ្វើតេស្តពិនិត្យការអភិវឌ្ឍ
  - កម្មវិធីទូរសព្ទ (The Health Insurance) → Health MOA → សុខភាពកុមារ(ពិនិត្យ) → ឡកចូលដោយប្រើវិញ្ញាបនបត្រ → ប់ពេញកម្រងសំណួរ/ទម្រង់ធ្វើតេស្តពិនិត្យការអភិវឌ្ឍ

  * សោតកម្មនេះអាចប្រើបានណុក្រាកែទ់ទាក់ទ់ងរវាងទារក/កុមារតូចៗ និងអ្នកថែទាំ (អ្នកកំណាងស្របច្បាប់) អាចផ្ទៀងផ្ទាត់ឬញ្ជាក់បាន។

<កម្រងសំណួរពហុភាសា និងទម្រង់ធ្វើតេស្តពិនិត្យការអភិវឌ្ឍ ការណែនាំសម្រាប់គ្រួសារពហុវប្បធម៌>

គេហទំព័រ (www.nhis.or.kr) → សេវាកម្មស៊ីវិល → ការណែនាំសេវាកម្មស៊ីវិល → ទាញយកទម្រង់នានាពីមុនមកទម្រង់ ប់ពេញ។ ហើយបញ្ជូនទម្រង់ទាំងនេះទៅស្ថាប័នពិនិត្យសុខភាព។

4 ការពិនិត្យសុខភាព

ការពិនិត្យសុខភាពទារក និងកុមារតូចៗនឹងត្រូវគ្នាទៅនឹងអាយុជាខែរបស់កូនអ្នក។

5 ទទួលបានការជូនដំណឹងអំពីលទ្ធផលពិនិត្យសុខភាព

បន្ទាប់ពីបញ្ចប់ការពិនិត្យសុខភាពហើយ ស្ថាប័នពិនិត្យសុខភាពនឹងផ្ញើជូនអ្នកនូវការជូនដំណឹងអំពីលទ្ធផល។

ជំនួយផ្នែកហិរញ្ញវត្ថុសម្រាប់ការវាយតម្លៃស៊ីជម្រៅលើការអភិវឌ្ឍរបស់ទារក និងកុមារតូចៗ

- រដ្ឋ និងរដ្ឋាភិបាលមូលដ្ឋានផ្តល់ជំនួយគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ការវាយតម្លៃស៊ីជម្រៅលើការអភិវឌ្ឍរបស់ទារក និងកុមារតូចៗ ដែលត្រូវបានណែនាំសម្រាប់ "ការវាយតម្លៃស៊ីជម្រៅ" ដោយផ្អែកលើលទ្ធផលនៃការធ្វើតេស្តពិនិត្យការអភិវឌ្ឍរបស់ពួកគេ។

  * សម្រាប់ព័ត៌មានលម្អិតអំពីសិទ្ធិទទួលបាន និងចំនួនទឹកប្រាក់ឧបត្ថម្ភ សូមសាកសួរព័ត៌មាននៅមណ្ឌលសុខភាពសាធារណៈដែលនៅជិតប់ផុត

- **ស្វែងរកមន្ទីរពេទ្យ/គ្លីនិកពិនិត្យសុខភាព**
  - គេហទំព័រ (www.nhis.or.kr) → Health MOA → ស្វែងរកស្ថាប័នពិនិត្យសុខភាព/មន្ទីរពេទ្យ → ព័ត៌មានមន្ទីរពេទ្យ/គ្លីនិក → ស្វែងរកស្ថាប័នវេជ្ជសាស្ត្រសម្រាប់ការវាយតម្លៃស៊ីជម្រៅលើការអភិវឌ្ឍរបស់ទារក និងកុមារតូចៗ

ការសាកសួរព័ត៌មាន

- **ការសាកសួរព័ត៌មានអំពីកម្មវិធី (សេវាធានារ៉ាប់រងសុខភាពជាតិ)**
  - 1577-1000 (ផ្ទួរកាត់លេខ 6 សម្រាប់ការប្រឹក្សាជាភាសាផ្សេងទៀត)
  - 033-811-2000 (ការប្រឹក្សាមានជាភាសាអង់គ្លេស , 中國語, tiếng Việt, O'zbekcha)
- **សេវាបកប្រែអត្ថបទ និងបកប្រែផ្ទាល់មាត់សម្រាប់គ្រួសារពហុវប្បធម៌ (វិទ្យាស្ថានកូរ៉េដើម្បីសុខភាពគ្រួសារ)**
  - 1577-1366 (មជ្ឈមណ្ឌលទំនាក់ទំនង Danuri)

ខ្មែរ